# គោលការណ៍សំខាន់បំផុតសំរាប់គ្រូគង្វាល

អ្នកនិពន្ធ រ៉ូហ្វ លេភិឡារ

## សំនួរដ៏ធំ

គ្រូគង្វាលគឺជាអ្នកដឹកនាំនៅក្នុងពួកជំនុំ ហើយសំរាប់អ្នកដឹកនាំទាំងអស់សំនួរដ៏សំខាន់ណាស់គឺ «តើ ខ្ញុំកំពុងតែនាំគេទៅណា?» ដូច្នេះសំនួរមួយដ៏សំខាន់ណាស់សំរាប់គ្រូគង្វាលគឺ «តើ ខ្ញុំកំពុងតែនាំសមាជិកនៃពួកជំនុំទៅណា?» បើសិនជាយើងមិនអាចឆ្លើយសំនួរនោះយ៉ាងច្បាស់ នោះយើងមិនអាចដឹកនាំយ៉ាងល្អបានទេ។

## ចម្លើយដ៏ច្បាស់និងសាមញ្ញ

ចម្លើយដ៏ច្បាស់និងសាមញ្ញនៅក្នុងសញ្ញាថ្មីចំពោះសំនួរ «តើ ខ្ញុំកំពុងតែនាំសមាជិកនៃពួកជំនុំទៅណា?» គឺព្រះយេស៊ូវ។ ហាក់ដូចជានេះជាចម្លើយយ៉ាងជាក់ស្តែង ប៉ុន្តែនេះគឺជាចម្លើយដែលមនុស្សប្រញាប់ភ្លេច។ អ្នកដឹកនាំអាចបញ្ឆោតខ្លួនហើយគិតថា គេនាំសមាជិកទៅព្រះគ្រីស្ទ ប៉ុន្តែ នៅក្នុងចិត្តហេតុដែលជំរុញអោយគេធ្វើការដឹកនាំ គឺដើម្បីដឹកនាំសមាជិកទៅគេខ្លួនឯង។ នេះគឺជាអាកប្បកិរិយាដែលខុស។

ចូរអាន អេភេសូរ ៤:១១-១៦។ នៅអត្ថបទនេះលោកប៉ុលបង្រៀនថា ព្រះគ្រីស្ទបានប្រទានអ្នកដឹកនាំនៅក្នុងពួកជំនុំប្រយោជន៍ឲ្យគេនឹងសាងព្រះកាយរបស់ព្រះគ្រីស្ទទៅជាមនុស្សពេញវ័យនៅក្នុងព្រះគ្រីស្ទ ហើយនេះនឹងនាំអោយយើងបានផ្គុំគ្នា ជៀសវាងពីនិងមិនតាមសេចក្តីបង្រៀនក្លែងក្លាយ។ គោលបំណងទាំងនេះបានកើតឡើងដោយយើងនិយាយនិងប្រតិបត្តិតាមសេចក្តីពិតដោយចិត្តស្រឡាញ់ (១៥)។

## ការអនុវត្តន៍: គ្រូគង្វាលត្រូវប្រតិបត្តិតាមនិងប្រកាសព្រះគ្រីស្ទ

ការអនុវត្តន៍មួយដ៏ច្បាស់ដែលមកពីគោលការណ៍ទីមួយនៅខាងលើគឺ គ្រូគង្វាលត្រូវប្រតិបត្តិតាមព្រះគ្រីស្ទនៅក្នុងជីវិតខ្លួនឯង ប្រយោជន៍ដើម្បីគេធ្វើជាគំរូល្អចំពោះគ្រីស្ទបរិស័ទ ហើយការអនុវត្តន៍មួយទៀតដ៏ច្បាស់គឺគេត្រូវប្រកាសព្រះគ្រីស្ទនៅក្នុងពួកជំនុំផងដែរប្រយោជន៍ដើម្បីនាំគេទៅព្រះគ្រីស្ទ។ លោកប៉ុលបានសរសេរនៅក្នុង កូល៉ុស ១:២៨ *យើងខ្ញុំប្រកាសប្រាប់ទ្រង់* (ព្រះគ្រីស្ទ) *ទាំងទូន្មានដល់គ្រប់មនុស្ស ហើយទាំងបង្រៀនដល់គ្រប់មនុស្ស ដោយគ្រប់ទាំងប្រាជ្ញា ដើម្បីឱ្យបានថ្វាយគ្រប់មនុស្ស ជាដង្វាយគ្រប់លក្ខណ៍ក្នុងព្រះគ្រីស្ទ*។ នេះគឺជាសេចក្តីសង្ខេបដ៏ល្អអំពីសកម្មភាពនិងគោលបំណងនៃគ្រូគង្វាល។ គេមានភារកិច្ចប្រកាសព្រះគ្រីស្ទដោយយល់ដល់គោលបំណងគឺយើងទាំងអស់គ្នាបានគ្រប់លក្ខណៈក្នុងអង្គព្រះគ្រីស្ទ។

## ព្រះគ្រីស្ទ គឺជាទីកណ្តាលនិងគោលបំណងនៃព្រះគម្ពីរ

នៅក្នុង លូកា ២៤:២៥-២៧,៤៤-៤៦ ព្រះយេស៊ូវបានបញ្ជាក់ប្រាប់ពួកសិស្សថា សញ្ញាចាស់ទាំងមូលគឺអំពីព្រះគ្រីស្ទផ្ទាល់។ ព្រះអង្គក៏បំភ្លឺចិត្តគំនិតគេអោយយល់អត្ថន័យគម្ពីរសញ្ញាចាស់ ហើយការយល់អត្ថន័យគម្ពីរសញ្ញាចាស់គឺជាការយល់ថា គម្ពីរសញ្ញាចាស់ទាំងមូលគឺអំពីព្រះគ្រីស្ទ ជាពិសេសការសុគតនិងការរស់ឡើងវិញរបស់ទ្រង់។

នៅក្នុង ធីម៉ូថេ ទី២ ៣:១៥ លោកប៉ុលសរសេរថា ព្រះគម្ពីរទាំងមូលគឺបានសរសេរទុកប្រយោជន៍ដើម្បីនាំយើងទៅព្រះគ្រីស្ទ ហើយទទួលសេចក្តីសង្គ្រោះនៅក្នុងព្រះគ្រីស្ទ។ ដូច្នេះហើយ គោលបំណងនៃព្រះគម្ពីរគឺនាំយើងទៅព្រះគ្រីស្ទ ហើយនេះជាគោលបំណងនិងភារកិច្ចរបស់គ្រូគង្វាលផងដែរ គឺនាំពួកជំនុំទៅព្រះគ្រីស្ទ។

ឧបមាថាម្នាក់ត្រូវបង្រៀនពីសៀវភៅមួយហើយអ្នកនោះមានគោលបំណងនៅក្នុងមេរៀនដែលខុសគ្នានឹងគោលបំណងនៃសៀវភៅនោះ។ នោះជាសកម្មភាពដែលឥតប្រយោជន៍ហើយខុសពីព្រោះគ្រូបង្រៀននិងសៀវភៅដែលគាត់បង្រៀនមានគោលបំណងខុសគ្នា។ ខ្លឹមសារនៃមេរៀនខុសគ្នានឹងខ្លឹមសាររបស់សៀវភៅ។ គ្រូគង្វាលនិងអ្នកដឹកនាំនៅពួកជំនុំត្រូវបង្រៀននិងអធិប្បាយព្រះគម្ពីរ ហើយព្រះគម្ពីរនោះគឺជាសៀវភៅ។ បើសិនជាគ្រូគង្វាលមានគោលបំណងនៅក្នុងការបង្រៀនរបស់គាត់ដែលខុសគ្នានឹងគោលបំណងរបស់ព្រះគម្ពីរ នោះឥតមានប្រយោជន៍។ ប៉ុន្តែ បើសិនជាគ្រូគង្វាលនិងព្រះគម្ពីរមានគោលបំណងតែមួយនោះមានប្រសិទ្ធភាព។ មធ្យោបាយរបស់គ្រូគង្វាលក្នុងភារកិច្ច ដឹកនាំសមាជិកទៅព្រះគ្រីស្ទគឺ បង្រៀនអធិប្បាយនិងប្រកាសព្រះបន្ទូល គឺជាព្រះគម្ពីរ ហើយព្រះគម្ពីរគឺជាឧបករណ៍ត្រឹមត្រូវពីព្រោះតួនាទីរបស់ព្រះគម្ពីរគឺធ្វើបន្ទាល់អំពីព្រះគ្រីស្ទ ទាំងសញ្ញាចាស់និងសញ្ញាថ្មី។

ទោះយ៉ាងណាក៏ដោយ ជារឿយៗគ្រីស្ទបរិស័ទ សូម្បីតែគ្រូគង្វាល មិនសូវយល់អំពីរបៀបដែលសញ្ញាចាស់បានចង្អុលទៅចំពោះព្រះគ្រីស្ទ។ ការយល់ដឹងនេះគឺជាការសំខាន់ណាស់។ ដូច្នេះហើយ យើងផ្តល់យោបល់ថា ចូរអានឯកសារអំពី*ប្រកាសព្រះគ្រីស្ទពីសញ្ញាចាស់។*